**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

# កំណត់ហេតុ
## កិច្ចប្រជុំពិភាក្សាផ្ទៃក្នុងថ្នាក់ដឹកនាំ និងវឌ្ឍនភាពការងារ
## នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ថ្ងៃសុក្រ ប្រាំកើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបបី ត្រូវនឹងថ្ងៃទី ប្រាំពីរ ខែមិថុនា ឆ្នាំពីពាន់ដប់ប្រាំបួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក នៅសាលប្រជុំ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានរៀបចំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងថ្នាក់ដឹកនាំ និងវឌ្ឍនភាពការងារ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៊ុណ្ណា សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** ដោយមានការអញ្ជើញចូលរួមពីះ

១.ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ុន រ៉ូ អគ្គលេខាធិការរង គ.ជ.ប.ជ
២.ឯកឧត្តម ឧត្តមសេនីយ៍ឯក យឹម វិរៈ អគ្គលេខាធិការរង គ.ជ.ប.ជ
៣.ឯកឧត្តម ឧត្តមសេនីយ៍ឯក យ៉ែម ច័ន្ទណារុំ អគ្គលេខាធិការរង គ.ជ.ប.ជ
៤.ឯកឧត្តម ឧត្តមសេនីយ៍ទោ អ៊ូ ម៉ានីវ៉ា អគ្គលេខាធិការរង គ.ជ.ប.ជ

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត អគ្គលេខាធិការ គ.ជ.ប.ជ** មានប្រសាសន៍ស្វាគមន៍ចំពោះវត្តមាន ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ ដែលមានវត្តមាននាពេលនេះ។ លោកជំទាវ ប្រធានអង្គប្រជុំបានអនុញ្ញាតជូន ឯកឧត្តម អគ្គលេខាធិការរង លើកជាមតិយោបល់ស្តីពីវឌ្ឍនភាពការងារប្រចាំថ្ងៃដែលបានអនុវត្តកន្លងមក បញ្ហាប្រឈម និងទិសដៅ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម វិរៈ** អគ្គលេខាធិការរង គ.ជ.ប.ជ បានលើកឡើងអំពីលទ្ធផលការងារដែលបានអនុវត្តកន្លងមក និងការងារដែលត្រូវអនុវត្តបន្តគឺ ពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធកិច្ចការងារអនុវត្តច្បាប់ ជាពិសេសតាមបណ្តាខេត្ត ដែលខ្វះការយល់ដឹងអំពីការជួញដូរមនុស្ស។ **ឯកឧត្តម** បានបញ្ជាក់ថា ការចុះបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់ គឺអាស្រ័យលើថវិកា ព្រោះខេត្តនីមួយៗពុំមានថវិកាសម្រាប់ការងារបណ្តុះបណ្តាលនោះទេ ពីមុនមក គឺមានអង្គការក្រៅរដ្ឋាភិបាលជួយខ្លះ ប៉ុន្តែគេជួយតែបណ្តាខេត្តគោលដៅប៉ុណ្ណោះ ដូច្នេះយើងត្រូវចុះបណ្តុះបណ្តាលឲ្យបានគ្រប់ខេត្តទាំងអស់។ **ឯកឧត្តម** មានមតិបន្ថែមថា មន្ត្រី នៃអគ្គលេខាធិការដ្ឋានយើងចំនួនច្រើនពួកគាត់ពុំមានឆន្ទៈក្នុងការបំពេញភារកិច្ចទេ តែក៏មានមន្ត្រីខ្លះគាត់មានឆន្ទៈធ្វើការងារដែរ ហើយមន្ត្រីរបស់យើងនៅពុំទាន់មានសមត្ថភាពក្នុងការអនុវត្តការងារនៅឡើយចាប់ពីមន្ត្រីរហូតដល់ថ្នាក់ដឹកនាំ។ យើងចង់ឲ្យមន្ត្រីរបស់យើងមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញការងារនេះ។ **ឯកឧត្តម** បានស្នើឲ្យលេខាធិការដ្ឋានធ្វើការរៀបចំឯកសារសម្រាប់ធ្វើការបណ្តុះបណ្តាលជំនាញ ក៏ដូចជានីតិវិធីអនុវត្តការងារដល់មន្ត្រី នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ឯកឧត្តម មានប្រសាសន៍ថា ពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពដល់មន្ត្រីត្រូវជួយបង្ហាត់បង្រៀនពួកគាត់ឲ្យបានយល់លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងអំពើរំលោភបំពាននានា។

ចំពោះការចូលរួមពីបណ្តាក្រសួងស្ថាប័ន និងអង្គការដៃគូពាក់ព័ន្ធនានា ឯកឧត្តមបានបញ្ជាក់ថា អង្គការពុំមានសិទ្ធិមកធ្វើការបណ្តុះបណ្តាលផ្នែកច្បាប់ណាមួយដល់មន្ត្រីយើងទេ គឺអង្គការត្រូវធ្វើការសហការជាមួយយើង ហើយចំពោះឯកសារពាក់ព័ន្ធនានាត្រូវតែសរសេរជាភាសាខ្មែរ មិនត្រូវសរសេរជាភាសាបរទេសឡើយ។ ចំពោះការងារទំនាក់ទំនងផ្ទៃក្នុង នៃអគ្គលេខាធិការដ្ឋានយើងជាពិសេសក្រុមការងារទាំង៦(អន្តរក្រសួង) យើងពុំបានដឹងថាក្រសួង ស្ថាប័នទាំងនោះកំពុងធ្វើអ្វី? ហើយមានដំណើរការដល់ណាឡើយ យើងចង់ឲ្យពួកគាត់សហការជាមួយយើង ផ្តល់របាយការណ៍ពាក់ព័ន្ធមកយើងផង។ **ឯកឧត្តម** បានបន្ថែមថា គាំទ្រក្នុងការបង្កើតក្រុមប្រឹក្សាវិន័យនៅក្នុងអគ្គលេខាធិការដ្ឋានយើងដើម្បីពង្រឹងវិន័យ និងសេចក្តីថ្លៃថ្នូរនៅក្នុងអង្គភាព។ **ឯកឧត្តម** បានបញ្ជាក់ពីសិទ្ធិ តួនាទីភារកិច្ចរបស់ថ្នាក់ដឹកនាំថា អគ្គលេខាធិការ និងអគ្គលេខាធិការរង គឺជាម្ចាស់អង្គភាព ឬស្ថាប័ន មានសិទ្ធិបញ្ជាទៅគ្រប់មន្ត្រីទាំងអស់ ប្រធាន និងអនុប្រធាននាយកដ្ឋានមានសិទ្ធិបញ្ជាតែមន្ត្រីនៅក្រោមឱវាទក្នុងនាយកដ្ឋានខ្លួនតែប៉ុណ្ណោះ មិនអាចបញ្ជាទៅមន្ត្រីនៅនាយកដ្ឋានផ្សេងបានទេ។ ឯកឧត្តម បានសំណូមពរឲ្យអគ្គលេខាធិការរងទាំងអស់ត្រូវមានជំនួយការ និងអ្នកបើករថយន្តម្នាក់ជៀសវាងមានបញ្ហាដោយថាហេតុណាមួយកើតឡើងពេលកំពុងបើកបរដោយខ្លួនឯង។

ឯកឧត្តម **ឧត្តមសេនីយ៍ឯក ស៊ុន រ៉ូ** អគ្គលេខាធិការរង គ.ជ.ប.ជ មានប្រសាសន៍ឯកភាពការលើកឡើងរបស់ឯកឧត្តម **ឧត្តមសេនីយ៍ឯក យឹម វិរៈ**។ ឯកឧត្តម បានលើកឡើងពីផែនការសកម្មភាពការងារប្រចាំថ្ងៃ និងការពង្រឹងសមត្ថភាពដល់មន្ត្រីរបស់យើង ក៏ដូចជាមន្ត្រីតាមបណ្តាខេត្តនានា គឺត្រូវមានកញ្ចប់ថវិកាផងដែរ។ **ឯកឧត្តម** បានបញ្ជាក់ថា ចំពោះការងារក្រុមបង្ការ ទប់ស្កាត់ គឺមិនមានបញ្ហាអីទេទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការងាររបាយការណ៍ប្រចាំខែ។ **ឯកឧត្តម**បន្ថែមថា ដើម្បីអនុវត្តការងារឲ្យរលូន គឺត្រូវពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធ ត្រូវចេះសាមគ្គី សហការគ្នា រកបញ្ហា និងដោះស្រាយបញ្ហា មន្ត្រីយើងមួយចំនួនធំពុំមានឆន្ទះធ្វើការងារទេ សូម្បីតែការចូលរួមប្រជុំជួររៀងរាល់ថ្ងៃចន្ទ ក៏ពុំមកចូលរួមដែរ។ ឯកឧត្តម សុំឲ្យមានការបណ្តុះបណ្តាលគ្រូបង្គោលឲ្យមានជំនាញត្រឹមត្រូវជាមុនសិន មុននឹងចុះធ្វើការបណ្តុះបណ្តាលដល់មន្ត្រីតាមបណ្តារាជធានី-ខេត្ត ព្រោះគ្រូបង្គោលខ្លះពុំទាន់មានជំនាញពិតប្រាកដនៅឡើយទេ។ ជាមួយការបណ្តុះបណ្តាលនេះ ខ្ញុំបានរៀបចំឯកសារមេរៀនដើម្បីបង្រៀនដល់មន្ត្រីយើងបានច្រើនហើយពាក់ព័ន្ធនឹងជំនាញប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បើមានអង្គភាពណាចង់បានឯកសារនេះ ត្រូវធ្វើលិខិតស្នើសុំត្រឹមត្រូវ។ **ឯកឧត្តម** បានលើកឡើងពីការគោរពវិន័យរបស់មន្ត្រីនៅក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ពុំទាន់ល្អ មានភាពធូររលុង និងពុំមានចំណាត់ការលើមន្ត្រីណាដែលធ្វើខុសពីវិន័យរបស់អង្គភាពនៅឡើយ យើងគួរតែបង្កើតក្រុមប្រឹក្សាវិន័យនៅក្នុងអគ្គលេខាធិការដ្ឋានយើង និងអនុវត្តឲ្យបានម៉ឺងម៉ាត់បំផុត យើងមិនត្រូវបង្កើតហើយមិនអនុវត្តនោះទេ។ **ឯកឧត្តម**បានមានប្រសាសន៍បន្តពាក់ព័ន្ធនឹងការជូនដំណឹងនានារបស់លេខាធិការដ្ឋានដូចជាកិច្ចប្រជុំបន្ទាន់ណាមួយ សូមឲ្យមានប្រធានបទ ឬរបៀបវារៈត្រឹមត្រូវដើម្បីងាយស្រួលក្នុងការត្រៀមឯកសារមកចូលរួម។

ឯកឧត្តម **ឧត្តមសេនីយ៍ទោ អ៊ូ ម៉ានីរ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ មានប្រសាសន៍ឯកភាពលើការបង្កើតក្រុមប្រឹក្សាវិន័យ ដើម្បីពង្រឹងសមត្ថភាពការងារនៅក្នុងអង្គភាពយើង ពីព្រោះអង្គភាពយើងមានការចូលរួមពីអន្តរក្រសួង ស្ថាប័ន ត្រូវគោរពតួនាទី ភារកិច្ចតាមឋានានុក្រម និងគោរពវិន័យកងកម្លាំងនគរបាលជាតិ ០០៦ ត្រូវចេះសហការគ្នានៅក្នុងអង្គភាព ព្រោះសង្កេតឃើញថាអង្គភាពយើងពុំទាន់មានការសហការគ្នាបានល្អនោះឡើយ។

ឯកឧត្តម **ឧត្តមសេនីយ៍ឯក យ៉ែម ច័ន្ទណារុំ** អគ្គលេខាធិការរង គ.ជ.ប.ជ មានប្រសាសន៍អំពីការអនុវត្តការងារប្រចាំថ្ងៃ និងតួនាទីភារកិច្ចនៅក្នុងអគ្គលេខាធិការដ្ឋានយើង។ **ឯកឧត្តម** បានបញ្ជាក់ថា តាមក្រុមការងារ

នីមួយៗភាគច្រើនធ្វើការងារបានល្អ ទោះបីមានបញ្ហាបន្តិចបន្តួច ប៉ុន្តែជារួមល្អ។ **ឯកឧត្តម** ឯកភាពចំពោះការបង្កើតឲ្យមានការបណ្តុះបណ្តាលដល់មន្ត្រីរបស់យើង ហើយចំពោះការបណ្តុះបណ្តាលតាមបណ្តាខេត្ត យើងមានលទ្ធភាពថវិកាសម្រាប់ចំណាយប្រសិនបើ (១).មានកម្មវិធីច្បាស់លាស់ និងបានព្រៀងដាក់បញ្ចូលទៅក្នុងផែនការថវិកាប្រចាំឆ្នាំ។ (២).គម្រោងចំណាយត្រូវតែអទិភាព និងទទួលបានការយល់ព្រមផ្តល់ការចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ (៣).យើងមិនអាចនឹកឃើញចង់បណ្តុះបណ្តាល ហើយស្នើសុំបណ្តុះបណ្តាលភ្លាមៗនោះទេ។ (៤).យើងពុំអាចផ្តល់ថវិកាបេសកកម្ម ឬ សោហ៊ុយធ្វើដំណើរសម្រាប់មន្ត្រីសាលាខេត្ត ស្រុកបានទេ ប៉ុន្តែយើងមានថវិកាសម្រាប់ចំណាយបេសកកម្ម និងចំណាយផ្សេងៗជូនថ្នាក់ដឹកនាំ និងមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ប៉ុន្តែត្រូវអនុលោមតាមនីតិវិធីហិរញ្ញវត្ថុសាធារណៈ។ **ឯកឧត្តម** បានឆ្លើយបញ្ជាក់ពាក់ព័ន្ធនឹងការអញ្ជើញចូលរួមប្រជុំបន្ទាន់តាមរយៈប្រព័ន្ធ Telegram ឬតាមរយៈទូរស័ព្ទដៃ គឺធ្វើឡើងដោយសារថ្នាក់ដឹកនាំបានជម្រាបមកភ្លាមៗ ប៉ុន្តែវាស្ថិតក្នុងម៉ោង នៃការងារផងដែរ ដូច្នេះសូមមេត្តាអាធ្យាស្រ័យ។ ប៉ុន្តែបើគ្មានភាពចាំបាច់ និងបន្ទាន់ទេ លេខាធិការដ្ឋាននឹងធ្វើលិខិតអញ្ជើញ។

**លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណា សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ** មានប្រសាសន៍ថា៖ ក្នុងនាមយើងជាថ្នាក់ដឹកនាំ មុននឹងឲ្យគេគោរពយើង លុះត្រាតែយើងត្រូវគោរពខ្លួនឯងជាមុនសិន ឲ្យតម្លៃខ្លួនឯង និងឲ្យតម្លៃអ្នកដទៃផង ត្រូវយល់អំពីការងាររបស់ខ្លួនឯង ត្រូវបញ្ជាឲ្យចំគោលដៅ និងម៉ឺងម៉ាត់ ត្រូវសិក្សាអំពីអ្នកដទៃ ត្រូវដឹងអំពីចំណុចខ្វះខាតរបស់ខ្លួនឯង និងត្រូវបំពេញបន្ថែមនូវចំណុចខ្វះខាតទាំងអស់នោះ ត្រូវចេះសហការគ្នានៅក្នុងក្រុម អ្នកដឹកនាំ គឺទទួលខុស និងត្រូវ កុំទទួលតែត្រូវនោះ។ **លោកជំទាវ** បានធ្វើការចង្អុលបង្ហាញ និងណែនាំក្នុងការអនុវត្តការងារដូចខាងក្រោម៖

-គ្រប់ក្រុមនីមួយៗត្រូវរៀបចំការប្រជុំរៀងរាល់ ១ខែម្តង

-ឯកភាពឲ្យមានការបង្កើតក្រុមប្រឹក្សាវិន័យនៅក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

-រាល់របាយការណ៍តាមក្រុមនីមួយៗ សូមបញ្ជូនមកលេខាធិការដ្ឋាន ដើម្បីរៀបចំបញ្ជូនមកអគ្គលេខាធិការពិនិត្យ និងតាមដានការងារទាំងនោះ។

-រាល់សកម្មភាពការងាររបស់អគ្គលេខាធិការរងទាំងអស់ (កិច្ចប្រជុំ ឬបេសកកម្មនានា) ត្រូវផ្តល់ដំណឹងទៅលេខាធិការដ្ឋានឲ្យបានដឹងដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងឆ្លើយតបជូនថ្នាក់ដឹកនាំវិញ។

-ចំពោះការបណ្តុះបណ្តាល មេរៀនបណ្តុះបណ្តាល និងកម្មវិធីបណ្តុះបណ្តាលមន្ត្រីក្នុងអគ្គលេខាធិការដ្ឋានអំពីជំនាញពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមប្រគល់ជូន **ឯកឧត្តម ឧត្តមសេនីយ៍ឯក យឹម វិរៈ** និង**ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ុន រ៉ូ** ទទួលខុសត្រូវក្នុងការរៀបចំ និងបណ្តុះបណ្តាល។

01/07/19

ចុងបញ្ចប់ នៃកិច្ចប្រជុំ **លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ** មានប្រសាសន៍បញ្ជាក់ថា កិច្ចប្រជុំថ្នាក់ដឹកនាំ និងអគ្គលេខាធិការរងទាំងអស់ នឹងត្រូវធ្វើការជួបប្រជុំគ្នានៅរៀងរាល់មួយខែម្តង។

កិច្ចប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងសាមសិបនាទី ថ្ងៃខែឆ្នាំដដែល។

ថ្ងៃពុធ ២រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩
**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ត្រី.សៅ ស៊ីនួន

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណា សំខាន់